# កម្មវិធីគាំទ្រសេវាអប់រំកុមារដែលរស់នៅតំបន់ដាច់ស្រយាល
# (អេស្កាប់)

Educational Quality Improvement Program
Classrooms • Schools • Communities

# សិក្ខាសាលាគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ

## កម្មវិធីសំរាប់ស៊ីហ្វាក់ថ្មី ឆ្នាំទី២

# ព្រាងឯកសារតម្រង់ទិស

**ការចូលរួមរបស់គណៈកម្មាធិការមូលដ្ឋាន**
**រួមចំណែកលើកកំពស់បរិយាកាសសិក្សាតាមបែបកុមារមេត្រី**

ខែមិថុនា ឆ្នាំ២០០៦

# មាតិកា


| ល.រ. | ខ្លឹមសារ | រយៈពេល | ទំព័រ |
|---|---|---|---|
| | **ថ្ងៃទី១** | | |
| 1 | ការចាប់ផ្តើម និងគោលបំណងសិក្ខាសាលា | 30 នាទី | |
| 2 | ការអប់រំសម្រាប់ទាំងអស់គ្នា | 30 នាទី | |
| 3 | ការស្រមៃដល់សាលារៀនដែលល្អវិសេស (សាលាកុមារមេត្រី) | 90 នាទី | |
| 4 | អ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមចំណែកក្នុងការលើកកំពស់គុណភាពអប់រំ | 45 នាទី | |
| 5 | រំលឹកពីកម្មវិធី អេស្កាប់ | 60 នាទី | |
| 6 | ការចូលរួមចំនែករបស់គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ ក្នុងការលើកកំពស់គុណភាពអប់រំ នៅមូលដ្ឋានរបស់ខ្លួន។ | 60 នាទី | |
| 7 | ការរៀបចំផែនដើម្បីចូលរួមក្នុងសកម្មភាពកែលំអរកំរងសាលារៀន | 45 នាទី | |
| | **ឧបសម្ព័ន្ធ** | | |
| ឧ.1 | ឯកសារស្តីអំពីសាលាកុមាមេត្រី (និយមន័យ និងសមាគទាំង៦) | | |
| ឧ.2 | អ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមចំណែកក្នុងការលើកកំពស់គុណភាពអប់រំ | | |
| ឧ.3 | តួនាទី និងការទទួលខុសត្រូវរបស់ គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ (CEFAC) ក្នុងការលើកកំពស់គុណភាពអប់រំ | | |
| ឧ.4 | តារាងម៉ាទ្រិច សម្រាប់រៀបចំផែនការសកម្មភាព ក្នុងដើមឆ្នាំទី២ | | |


## គោលបំណងសិក្ខាសាលា

- បង្កើតជាវេទិការមួយដែលអ្នកចូលរួមអាចពិភាក្សាគ្នា និង ធ្វើការវិភាគលើបញ្ហាអប់រំ និង ផលបះពាល់លើសុខមាលភាពប្រជាជនជាពិសេសលើស្ត្រី និង កុមារី។
- អ្នកចូលរួមអាចរៀបរាប់បានពី បញ្ញត្តិសាលាកុមារមេត្រី និង អត្ថន័យនៃអ្នកពាក់ពន្ធ័
- អ្នកចូលរួមអាចអាចធ្វើការបកស្រាយពីគោលបំណង និង លក្ខណៈសម្បត្តិសំខាន់ៗ នៃកម្មវិធី អេស្កាប់។
- អ្នកចូលរួមអាចកំនត់ទៅលើតួនាទី និងការទទួលខុសត្រូវរបស់សមាជិកគណៈ កម្មាធិការអប់រំសម្រាប់ទាំងអស់ គ្នាថ្នាក់ឃុំ (CEFAC) ដែលពាក់ពន្ធ័ទៅនឹងផែនការកំរងសាលារៀន និង ការកែលំអកំរងសាលារៀន។

## គម្រោងមេរៀន

| ១. ការចាប់ផ្តើមសិក្ខាសាលា | | |
|---|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេប** | **១.១ ការណែនាំបង្ហាញខ្លួន** ៖វគ្គនេះជាការចាប់ផ្តើមដោយអ្នកសម្របសម្រួល និងសិក្ខាកាម ណែនាំខ្លួនដើម្បីស្គាល់គ្នា បង្ហាញខ្លឹមសារ និងគោលបំណងសិក្ខាសាលា ព្រមទាំងផ្តល់ឱកាស ដល់សិក្ខាកាម ក្នុងការបង្កើតបទបញ្ជាផ្ទៃក្នុងសម្រាប់សិក្ខាសាលា ដើម្បីធានាឱ្យមានការ ចូលរួមពេញលេញ សំដៅធ្វើឱ្យសិក្ខាសាលាមានដំណើរការល្អ ។ | |
| **រយៈពេលៈ** | ២០នាទី | |
| **សម្ភារដែលត្រូវការៈ** | គ្មាន | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
| ▪ សិក្ខាកាមបានស្គាល់គ្នាកាន់តែច្បាស់ ។ | <u>ការណែនាំឱ្យស្គាល់គ្នា</u><br>▪ អ្នកសម្របសម្រួលចាប់ផ្តើមដោយការស្វាគមន៍យ៉ាងកក់ក្តៅដល់សិក្ខាកាមទាំងអស់ ហើយបន្តដោយការណែនាំខ្លួនម្នាក់ម្តងៗ ។<br><u>ការចាត់ចែងអង្គុយតាមក្រុម</u> | ▪ សិក្ខាកាម និង ក្រុមអ្នក សម្របសម្រួល ណែនាំខ្លួន ។ |
| ▪ សិក្ខាកាមត្រូវបានរៀប អោយអង្គុយតាមរបៀបមួយដែលងាយស្រួលក្នុងការពិភាក្សា និង ចូលរួម ។ | ▪ បន្ទាប់ពីការណែនាំ អ្នកសម្របសម្រួល គួររៀបចំ សិក្ខាកាមអោយអង្គុយតាមក្រុម ដូចជាតាមឃុំ រឺ កម្រងដែលគេមក ។<br><u>បទបញ្ជាផ្ទៃក្នុងសិក្ខាសាលា</u><br>▪ អ្នកសម្របសម្រួលបំផុសឱ្យសិក្ខាកាមបង្កើតបទបញ្ជាផ្ទៃក្នុងដោយខ្លួនឯង ។ បទបញ្ជានេះ អាចមានចំណុចដូចខាងក្រោម៖ | ▪ សិក្ខាកាមជួយរៀបចំតុ ដើម្បីអង្គុយតាមក្រុម ។ |
| ▪ សិក្ខាកាមឯកភាពលើបទ បញ្ជាសម្រាប់ដំណើរការសិក្ខាសាលា ។ | ♦ ពេលវេលា( ម៉ោងចូល និងម៉ោងចេញ ) ម៉ោងសម្រាក<br>♦ គ្រប់គ្នាត្រូវគោរពពេលវេលា<br>♦ មិនជក់បារីក្នុងបន្ទប់សិក្ខាសាលា<br>♦ និយាយម្តងម្នាក់ ដោយមិនដណ្តើមគ្នានិយាយ<br>♦ បង្ហាញការគោរពមតិយោបល់អ្នកដទៃ<br>♦ ព្យាយាមស្តាប់ និងបញ្ចេញយោបល់<br>♦ ផ្តល់ព័ត៌មានទាក់ទងនឹងការងាររដ្ឋបាលឬថវិកា ដូចជា per diem ឬសោហ៊ុយធ្វើដំណើរ ជាដើម ។ល ។<br>○អ្នកសម្របសម្រួលអានបទបញ្ជានេះឡើងវិញ ដើម្បីបានការឯកភាពពីក្រុមទាំងមូល រួចហើយបិទវា នៅលើជញ្ជាំង ។ | ▪ សិក្ខាកាមផ្តល់យោបល់ តាមការយល់ឃើញផ្ទាល់ខ្លួន ។<br>○សិក្ខាកាមកែសម្រួលបទបញ្ជាផ្ទៃ ដែលបានបង្កើត បើមានការចាំបាច់ ។ |

| | | |
|---|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេប**<br><br><br>**រយៈពេលៈ** | **១.២ គោលបំនងសិក្ខាសាលាៈ** វគ្គនេះ គឺជាការបង្ហាញពីគោលបំណង របស់សិក្ខាសាលា ដល់សិក្ខាកាម ដើម្បីឱ្យពួកគេបានដឹង និងគិតពីការរំពឹងទុករបស់ខ្លួនចំពោះសិក្ខាសាលានេះ ហើយត្រៀមខ្លួនចូលរួមក្នុងការពិភាក្សាក្នុងវគ្គបន្តបន្ទាប់។<br>១០នាទី | |
| **សម្ភារដែលត្រូវការៈ** | ○ ផ្ទាំងក្រដាសធំ ដែលមានសរសេរពីគោលបំណង និងខ្លឹមសារសិក្ខាសាលា | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
| ▪ សិក្ខាកាមអាចពន្យល់អំពីគោលបំនងសិក្ខា-សាលា។ | ▪ អ្នកសម្របសម្រួលបិទផ្ទាំងក្រដាសធំ ដែលមានសរសេរសេចក្តីសង្ខេបអំពីគោលបំណង និងខ្លឹមសារមេរៀន។<br>▪ ពិនិត្យមើលខ្លឹមសារនៅលើប៉ុស្ទ័រនោះ ជាមួយសិក្ខាកាម។<br>▪ ទុកពេលឱ្យសិក្ខាកាមសួរសំណួរ។<br>▪ អ្នកសម្របសម្រួលបកស្រាយសំណួរ បើមាន។ | ▪ សិក្ខាកាមពិនិត្យមើល ខ្លឹមសារនៅលើប៉ុស្ទ័រ ជាមួយអ្នកសម្របសម្រួល។<br>▪ សិក្ខាកាមសួរសំណួរ បើមានចម្ងល់។ |
| **២. ការអប់រំសម្រាប់ទាំងអស់គ្នា** | | |
| **ខ្លឹមសារនិងសេចក្តីសង្ខេប**<br><br><br>**រយៈពេលៈ** | **៣ៈ ការអប់រំសម្រាប់ទាំងអស់គ្នាៈ**មេរៀននេះ ផ្តល់ដល់សិក្ខាកាមនូវការយល់ដឹងអំពីប្រវត្តិនៃការ អប់រំសម្រាប់ទាំងអស់គ្នា និងគោលការណ៍សំខាន់ៗនៃផែន ការអប់រំសម្រាប់ទាំងអស់គ្នា។<br><br>៣០នាទី | |
| **សម្ភារដែលត្រូវការៈ** | គ្មាន | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
| សិក្ខាកាមអាចៈ<br>▪ យល់ដឹងអំពីបញ្ញត្តិទាក់ទងនឹងការអប់រំសម្រាប់ទាំងអស់គ្នា។<br>▪ រៀបរាបអំពីគោលនយោបាយនៃការអភិវឌ្ឍវិស័យអប់រំ។<br>▪ រៀបរាប់ពីគោល-ការណ៍អភិវឌ្ឍសំខាន់ | **៣.១. ការអប់រំសម្រាប់ទាំងអស់គ្នាជាអ្វី?**<br>ក្នុងក្រុមធំៈ<br>▪ អ្នកសម្របសម្រួលផ្តើមសួរសំណួរភ្ជាប់ពីមេរៀនមុន ដើម្បីចូលបរិបទថ្មីៈ<br><u>សំណួរៈ</u> តើកុមារនៅលើពិភពលោករួមទាំងកម្ពុជា បានទទួលការអប់រំ **គ្រប់ៗគ្នា** ឬទេ?<br>▪ អ្នកសម្របសម្រួលអាចពន្យល់បន្ថែម ដោយប្រើព័តិមាននៅក្នុងកំនត់សំគាល់ស្តីអំពីតួលេខ នៅផ្នែកខាងក្រោម។<br>▪ អ្នកសម្រសម្រួលពន្យល់ៈ | ▪ ចម្លើយរំពឹងទុកៈ នៅសតវត្សទី២១នេះ កុមារ ទូទាំងពិភពលោក ចំនួន១៣០ លាននាក់មិនបានទទួលការអប់រំមូលដ្ឋាន ក្នុងនោះ១,៣ ជាកុមារី [១]។ |

[១] ប្រភព : ឯកសារយុទ្ធនាការអប់រំពិភពលោក (GCE Pack, NOVIB 2004) ឆ្នាំ២០០៤

| | | |
|---|---|---|
| ៧ ក្នុងផែនការអប់រំ សម្រាប់ទាំងអស់គ្នា។ | ការអប់រំប្រកបដោយគុណភាពគឺជាសិទ្ធិមូលដ្ឋានរបស់មនុស្សជាតិ។ តែទោះជាយ៉ាងនេះក៏ដោយក៏មានកុមារជាងមួយលាននាក់នៅទូទាំងពិភពលោកនៅមិនទាន់បានទទួលការអប់រំជាមូលដ្ឋាន ហើយ២ភាគ៣នៃចំនួននោះគឺជាកុមារី។ នៅក្នុងប្រទេសកម្ពុជា កុមារា និង កុមារីចាប់ផ្តើមបោះជំហានចូលសាលាក្នុងអត្រាស្មើគ្នា ហើយពួកគេស្ថិតនៅក្នុងកំរិតអត្រាស្មើគ្នារហូតដល់អាយុ១០ឆ្នាំ។តែទោះជាយ៉ាងណាក៏ដោយអត្រាចូលរៀនរបស់កុមារីចាប់ ផ្តើមធ្លាក់ចុះនៅក្រោមកុមារាភ្លាមក្រោយពី អាយុ ១០ ឆ្នាំ។ សម្រាប់ថ្នាក់ទី ៤-៥ អត្រាបោះបង់មានកំរិតខ្ពស់សម្រាប់កុមារ ដែលគេត្រូវការបំផុតជាពិសេសកុមារី។ ព្រោះហេតុនេះហើយទើបមានសន្និសិទអន្តរជាតិស្តីការអប់រំសម្រាប់ទាំងអស់គ្នា នៅ Jomtiem និងថ្មី១បំផុតនៅ Dakar, Senegal ដោយរួមទាំងប្រទេសកម្ពុជាផង បានធ្វើការសន្យាថាកុមារទាំងអស់នឹងទទួលបាននូវការអប់រំជាមូលដ្ឋានប្រកបទៅដោយគុណភាព នាឆ្នាំ ២០១៥។<br>▪ អ្នកសម្របសម្រួលអាចសួរសំនួរដដែលឡើងវិញដើម្បីពង្រឹងការយល់ដឹងរបស់អ្នកចូលរួម។<br>**៣.២. គោលនយោបាយនៃការអភិវឌ្ឍវិស័យអប់រំ**<br>▪ អ្នកសម្របសម្រួលបំផុសសំណួរ ក្នុងក្រុមធំ: តើក្រសួងអប់រំមានឯកសារផែនការអ្វីខ្លះ?<br>▪ អ្នកសម្របសម្រួលពន្យល់ត្រួស១អំពីផែនការនិមួយ១(តាមខ្លឹមសារនៅក្នុងប្រអប់ទី១) ស្តីអំពីគោលនយោបាយនៃការអភិវឌ្ឍវិស័យអប់រំ។<br>**៣.៣. គោលការណ៍អភិវឌ្ឍបីចំនុចសំខាន់១ ក្នុងផែនការអប់រំ សម្រាប់ទាំង អស់គ្នា**<br>▪ អ្នកសម្របសម្រួលពន្យល់ក្នុងក្រុមធំ: គោលការណ៍អភិវឌ្ឍក្នុងផែនការ អប់រំសម្រាប់ ទាំងអស់គ្នា មានបីសំខាន់១គឺ:<br>១.ការលើកកំពស់ប្រសិទ្ធភាពនិងគុណភាពអប់រំមូលដ្ឋាន<br>២. សមធមិក្នុងការទទួលការអប់រំមូលដ្ឋាន<br>៣. ការពង្រឹងការធ្វើផែនការនិងការគ្រប់គ្រង | ▪ អ្នកចូលរួមផ្តល់ចម្លើយ: គឺជាចលនារបស់ពិភពលោក ដែលមានជាង១៨២ ប្រទេសចូលរួមក្នុងនោះ មានប្រទេសកម្ពុជាយើងផង ដើម្បីឱ្យកុមារ យុវជននិងមនុស្សពេញវ័យ គ្រប់រូបមានសិទ្ធិទទួលការ អប់រំមូលដ្ឋាន ដែលប្រកប ដោយគុណភាពនៅឆ្នាំ២០១៥។<br>▪ អ្នកចូលរួមផ្តល់ចម្លើយ<br>គោលនយោបាយអប់រំធំ១នៅកម្ពុជាយើង មាន៣ គឺ:<br>១. ផែនការអប់រំ សម្រាប់ ទាំងអស់គ្នា (EFA)<br>២. ផែនការយុទ្ធសាស្ត្រ វិស័យអប់រំ (ESP)<br>3.កម្មវិធីគាំទ្រវិស័យ អប់រំ (ESSP)<br>▪ អ្នកចូលរួមស្តាប់និងសួរសំណួរ |

| | | |
|---|---|---|
| | ៣.៤ .សង្ខេបនិងបូកសរុប<br>▪ អ្នកសម្របសម្រួលសួរសំណួររំលឹកឡើងវិញ ដើម្បីបញ្ជាក់ពីការយល់ដឹងរបស់អ្នកចូលរួម ។<br>១. ការអប់រំសម្រាប់ទាំងអស់គ្នាជាអ្វី?<br>២. គោលនយោបាយនៃការអភិវឌ្ឍវិស័យអប់រំ?<br>៣. គោលការណ៍អភិវឌ្ឍសំខាន់ៗ ក្នុងផែនការអប់រំ<br>▪ សម្រាប់ទាំងអស់គ្នា មានអ្វីខ្លះ? | |

## ៣. ការស្រមៃដល់សាលារៀនមួយដែលល្អវិសេស

| | |
|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេប :**<br><br>**រយៈពេល:** | វគ្គនេះផ្តល់ឱកាសឱ្យសិក្ខាកាម បង្កើនការយល់ដឹងរបស់ខ្លួន ទៅលើលក្ខណៈនៃសាលាកុមារមេត្រី និងសិក្សាអំពីគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និង កីឡា អំពីកម្មវិធីសាលាកុមារមេត្រី ដែលជាយុទ្ធវិធីមួយ ក្នុងការធ្វើឱ្យសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ២០១៥ ។<br>៩០ នាទី |
| **សម្ភារដែលត្រូវការ:** | ▪ ប័ណ្ណពណ៌ ដែលចំណងជើងនៃសមាសភាគនីមួយៗ (ប័ណ្ណមួយសម្រាប់ចំណងជើងមួយ)<br>▪ ឯកសារចែក - ឧបសម្ព័ន្ធទី១ " និយមន័យនិងសមាសភាគទាំង៦ នៃកម្មវិធីសាលាកុមារមេត្រី "<br>▪ ប័ណ្ណពណ៌ ប័ណ្ណស ហ្វឺត ស្កុត |

| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
|---|---|---|
| ▪ សិក្ខាកាមអាចបង្កើនការយល់ដឹងថែមទៀតទៅលើបញ្ញតិសាលាកុមារមេត្រីតាមរយៈការគិត ស្រមៃដល់សាលារៀន ដែលល្អវិសេស ។ | ▪ អ្នកសម្របសម្រួលឱ្យសិក្ខាកាមបិទភ្នែកស្រមៃដល់សាលារៀន មួយនៅក្នុងភូមិដែលគាត់រស់នៅ ប្រមាណ២ ឬ៣វិនាទី ។ នៅពេលស្របគ្នាដែលសិកាកាមបិទភ្នែកស្រមៃ អ្នកសម្របសម្រួលបំផុសសំណួរមួយម្តងៗ:<br>♦ តើអាគារសិក្សាមានសភាពដូចម្តេច?<br>♦ តើទីធ្លាសាលាយ៉ាងណាដែរ (ក្រៀមក្រោះ ខៀវស្រងាត់ ស្អាត/មិនស្អាតមាន/គ្មានអនាម័យមានសួនច្បារ មាន..)?<br>♦ តើនៅក្នុងថ្នាក់មានសភាពដូចម្តេចដែរ ?<br>♦ មានគ្រូគ្រប់គ្រាន់ទេ គ្រូមកបង្រៀនទៀងទាត់ទេ យកចិត្តទុកដាក់ទេ មានសម្ភារបង្រៀនទេ...?<br>♦ តើកុមារក្នុងភូមិមករៀនគ្រប់គ្នាទេ? សិស្សមានសៀវភៅ | ▪ សិក្ខាកាមស្រមៃដល់សាលារៀននៅក្នុងភូមិ ។<br><br>▪ សម្រាប់ចម្លើយរំពឹងទុក សូមមើលចំណុចលំអិត នៅក្នុង CFS ។ សិក្ខាកាម អាចលើកចំនុចស្រដៀងគ្នាជាទៀត ។ |

| | | |
|---|---|---|
| | ពុម្ភគ្រប់គ្នាទេ ពួកគេចេះជួយគ្នាទេ មានអនាម័យទេ...?<br>♦ តើកម្មវិធីសិក្សាធ្វើឱ្យកុមារចាប់អារម្មណ៏ឬទេ? ហេតុអ្វី?<br>♦ តើការគ្រប់គ្រងសាលា យ៉ាងណាដែរ? សាលាមានការប្រជុំញឹកញាប់ឬទេ?....<br>♦ តើ ឪពុកម្តាយ និងសហគមន៏ សហការជិតស្និទ្ធជាមួយសាលារៀនទេ? ចូលរួមអ្វីខ្លះ?<br>♦ ។ល ។<br>▪ ឱ្យសិក្ខាកាមចែករំលែកអ្វីដែលបានស្រមៃឃើញ ក្នុងក្រុមធំ ។<br>▪ អ្នកសម្របសម្រួលកត់ត្រាចំនុចសំខាន់ៗ នៅលើក្តារខៀន។ | |
| | ▪ បន្ទាប់មក ឱ្យសិក្ខាកាមគិតស្រមៃម្តងទៀត ដល់សាលា រៀនមួយដែលល្អវិសេស ដែលគាត់ចង់បាន។<br>▪ ពិនិត្យឡើងវិញពីការស្រមៃនេះ ដោយឱ្យសិក្ខាកាមផ្លាស់ប្តូរយោបល់គ្នា ក្នុងក្រុមធំ។<br>▪ កត់ត្រាចំនុចសំខាន់ៗ ដែលបានពីការពិភាក្សា នៅលើប័ណ្ណ។ ប័ណ្ណមួយសរសេរមួយចំណុច។<br>*សំគាល់: អ្នកសម្របសម្រួលអាចនាំសិក្ខាកាមធ្វើសកម្មភាពទាំងពីរខាងលើ គឺការស្រមៃសាលារៀននៅក្នុងភូមិ និងការស្រមៃសាលារៀនដែលល្អវិសេស ដែលគេចង់បាន ប្រសិនបើមានពេលវេលាគ្រប់គ្រាន់ ពុំនោះទេគឺធ្វើតែសកម្មភាពទី២ គឺការស្រមៃសាលារៀនដែលល្អវិសេស ដែលចង់បាន។* | ▪ សិក្ខាកាមនឹកគិតដល់សាលារៀន ដែលល្អហើយចែករំលែក ក្នុងក្រុម។ |
| | ▪ ពន្យល់សិក្ខាកាមថា ចំណុចល្អទាំងអស់ដែលពួកគាត់ស្រមៃនោះ គឺជាលក្ខណៈសាលាកុមារមេត្រី ដែលជាសគោលការណ៏របស់ក្រសួង ក្នុងការធ្វើឱ្យសម្រេចគោលដៅអប់រំសម្រាប់ទាំងអស់គ្នា ឆ្នាំ ២០១៥។ | ▪ សិក្ខាកាមវិភាគ និងសង្ខេប និយមន័យ សាលាកុមារមេត្រី ។ |
| | ▪ ចែកឧបសម្ព័ន្ធទី១ " និយមន័យនិងសមាសភាគទាំង៦ នៃកម្មវិធីសាលាកុមារមេត្រី" ឱ្យសិក្ខាកាមម្នាក់ៗ។ ពិនិត្យមើលនិយមន័យ ដោយឱ្យសិក្ខាកាមម្នាក់អានឮ ហើយទាំងអស់គ្នាសង្ខេបខ្លឹមសារ ដោយលើកចំណុចសំខាន់ៗ ហើយកត់ត្រានៅលើក្តារខៀន។<br>▪ បិទប័ណ្ណពណ៌ ដែលមានចំណងជើងសមាសភាគនីមួយៗ នៅ | ▪ សិក្ខាកាមយកប័ណ្ណ ទៅបិទលើជញ្ជាំង។<br>សិក្ខាកាមសួរ សំណួរបើមាន ចម្ងល់។ |

| | | |
|---|---|---|
| | លើជញ្ជាំង ហើយឱ្យសិក្ខាកាមលើកយកប័ណ្ណ ដែលបានពីសកម្មភាពមុន មកបិទឱ្យត្រូវនឹងសមាសភាគនីមួយៗ។<br>▪ បញ្ជាក់ដល់សិក្ខាកាមថាក្របខ័ណ្ឌការងាររបស់អេស្មាប់គឺផ្អែកលើគោលការណ៍ ឬគោលនយោបាយសាលាកុមារមេត្រីរបស់ក្រសួងអប់រំ។<br>▪ រំលឹកសិក្ខាកាម ថាឯកសារដែលចែក គឺឯកសារឧបសម្ព័ន្ធទី១ អាចជួយឱ្យពួកគេ កាន់តែយល់អំពីសាលាកុមារមេត្រីថែមទៀត នៅពេលដែលគេបានអានវា។ | |
| **៤. អ្នកពាក់ព័ន្ធសំខាន់ៗ ដែលរួមចំណែកក្នុងការលើកកំពស់គុណភាពអប់រំ** | | |
| **ខ្លឹមសារនិងសេចក្ដីសង្ខេប:** | វគ្គនេះផ្ដល់ឱកាសឱ្យសិក្ខាកាម កំណត់ថាតើអ្នកណាខ្លះជា អ្នកពាក់ព័ន្ធសំខាន់ៗ ទាក់ទងនឹងការងារអប់រំ ហើយតើអ្នកទាំងនោះ មានទំនាក់ទំនងគ្នាទៅវិញទៅមកដូចម្ដេច។ | |
| **រយៈពេល:** | ៦០ នាទី | |
| **សម្ភារដែលត្រូវការ:** | ▪ ផ្ទាំងក្រដាសធំ ប័ណ្ណពណ៌ ប័ណ្ណស ហ្វឺត ស្កុត កន្ត្រៃ<br>▪ ឯកសារចែក-ឧបសម្ព័ន្ធទី ២ " ដ្យាក្រាមអំពីអ្នកពាក់ព័ន្ធ"<br>▪ ឯកសារចែក-ឧបសម្ព័ន្ធទី ៣ " ម៉ាទ្រិចតួនាទី និងភារកិច្ចរបស់ CEFAC " (ទម្រង់ដែលមិនទាន់បំពេញ និង ទម្រង់ដែលបំពេញរួច ជាឧទាហរណ៍ ) | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
| ▪ សិក្ខាកាមអាចកំណត់អ្នកពាក់ព័ន្ធ សំខាន់ៗ ទាក់ទងនឹងការងារអប់រំ និងឆ្លុះបញ្ចាំង លើតួនាទីរបស់ខ្លួនក្នុងការគាំទ្រគុណភាពអប់រំ។ | <u>អ្នកពាក់ព័ន្ធសំខាន់ៗ ដែលចូលរួមក្នុងការងារអប់រំ</u><br>▪ អ្នកសម្របសម្រួលចាប់ផ្ដើមវគ្គនេះ ដោយសួរសំណួរ: តើកត្តាសំខាន់ៗអ្វីខ្លះ ដែលធ្វើឱ្យសាលារៀនមួយក្លាយជាសាលាកុមារមេត្រី?<br>▪ ទុកពេលឱ្យសិក្ខាកាមម្នាក់ៗ គិតរៀងៗខ្លួនមុននឹងឆ្លើយ។ ចម្លើយរំពឹងទុក រួមមានដូចជា:<br>♦ មានធនធានគ្រប់គ្រាន់(ថវិកា សម្ភារ ពេលវេលា មនុស្ស..)<br>♦ អភិបាលកិច្ចសាលារៀនល្អ (មានការប្រជុំគ្រូ សិស្ស មាតា បិតា សហគមន៍ មាន ផែនការសាលារៀនដែលធ្វើដោយ មានការចូលរួមគ្រូមកបង្រៀនទៀងទាត់ មានការលើកទឹកចិត្ត មានសម្ភារបង្រៀន និងរៀន មានការពិនិត្យតាមដាន និងស្វ័យវាយតម្លៃសាលារៀន....<br>♦ គ្រូមានឆន្ទៈ និងចាប់អារម្មណ៍លើការបង្រៀន....<br>♦ ឪពុកម្ដាយឱ្យតម្លៃលើការអប់រំ ជម្រុញកូននៅផ្ទះ...<br>♦ សិស្សមានសុខភាពល្អ មានអនាម័យ មានសុវត្ថិភាព.... | ▪ សិក្ខាកាមផ្ដល់ចម្លើយ (សូមមើលចម្លើយរំពឹងទុកនៅជួរចខាងឆ្វេងដៃ។ |

<table>
<tr>
<td></td>
<td>
♦មានទំនាក់ទំនងល្អ រវាងសាលារៀន និង សហគមន៍ ...<br>
♦ ។ល ។<br>
▪ ឱ្យសិក្ខាកាមផ្លាស់ប្តូរយោបល់ក្នុងក្រុមធំ ហើយសេសេរចំណុចសំខាន់ៗនៅលើក្តារខៀន ។ ផ្តល់ឱកាសឱ្យសិក្ខាកាមសួរនិងបំភ្លឺលើចំណុចនីមួយៗ ដើម្បីឱ្យបានយល់ច្បាស់ទាំងអស់គ្នា ។ ធ្វើដូចនេះ នឹងអាចឱ្យសិក្ខាកាមងាយក្នុងការគិតដល់ខ្លឹមសារនៃវគ្គក្រោយទៀត គឺនិយាយអំពីអ្នកពាក់ព័ន្ធសំខាន់ៗ ។<br>
▪ អ្នកសម្របសម្រួលបិទប័ណ្ណពណ៌មានរាងពងក្រពើ ដែលមានសរសេរពាក្យ" អ្នកពាក់ព័ន្ធសំខាន់ៗ" នៅចំកណ្តាលក្តារខៀន រួចហើយសួរថា: តើអ្នកណាខ្លះជា" អ្នកពាក់ព័ន្ធសំខាន់ ៗ" ? ហើយបន្ថែមប័ណ្ណមពណ៌មានរាងដូចគ្នានេះដែរ នៅជុំវិញប័ណ្ណទី១ ដោយសរសេរចំណុចដែលផ្តល់ដោយ សិក្ខាកាមជាមុនសិន មុននឹងបិទវា ។<br>
▪ ចែកឯកសារឧបសម្ព័ន្ធ ទី ២ ឱ្យសិក្ខាកាម ។<br>
<u>តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធសំខាន់ ៗ ចំពោះគុណភាពអប់រំ</u><br>
▪ អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា៤ក្រុម ហើយចែក - ឧបសម្ព័ន្ធទី ៣ក " ម៉ាទ្រិចតួនាទី និងភារកិច្ចរបស់ CEFAC "( ទម្រង់ដែលមិនទាន់បំពេញ) ឱ្យសិក្ខាកាមម្នាក់ៗ<br>
▪ ឱ្យសិក្ខាកាមផ្លាស់ប្តូរយោបល់ក្នុងក្រុមតូច ៗ ហើយសេសេរលទ្ធផលពិភាក្សា នៅជួរខាងស្តាំនៃតារាងដែលចែកឱ្យ ។<br>
▪ បញ្ចូល២ក្រុមចូលគ្នា ដើម្បីពិភាក្សាលើលទ្ធផលទាំង២ក្រុម រកមតិរួម ។ ក្រុមនីមួយៗសរសេលទ្ធផលពិភាក្សានៅ លើផ្ទាំងក្រដាសធំ ។<br>
▪ បូកសរុបសលទ្ធផល ដោយពិនិត្យមើលចំណុចស្រដៀងគ្នា និងចំណុចដូចគ្នា ។ ពិភាក្សាលើចំណុចខុសគ្នា ដើម្បីរកមតិរួម ឬ រកហេតុផល ដើម្បីបញ្ជាក់ ។<br>
▪ ចែកឯកសារឧបសម្ព័ន្ធ ទី ៣ខ ( ទម្រង់ដែលបំពេញរួច ) ឱ្យសិក្ខាកាម ។
</td>
<td>
▪ សិក្ខាកាមផ្តល់ចម្លើយ ដើម្បីឈានទៅបង្កើតដ្យាក្រាមមួយ ។ ចម្លើយរំពឹងទុកនៅក្នុងឧបសម្ព័ន្ធ ទី ២ ។<br>
<table>
<tr><th></th><th>CEFAC</th></tr>
<tr><td>សិស្ស</td><td></td></tr>
<tr><td>គ្រូ</td><td></td></tr>
<tr><td>នាយក</td><td></td></tr>
<tr><td>ក្រុមប្រឹ.ឃុំ</td><td></td></tr>
<tr><td>សហគមន៍</td><td></td></tr>
</table>
<br>
▪ សិក្ខាកាមសួរសំណួរ បើមាន ចម្ងល់ ។
</td>
</tr>
</table>

| ៥, រំលឹកពីកម្មវិធី អេស្កាប់ | | |
|---|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេប:**<br>**រយៈពេល:** | **៥:ការរំលឹកអំពីកម្មវិធីអេស្កាប់:**ដូចគ្នាដែរ នេះគឺជាមេរៀនរំលឹក។ សិក្ខាកាមនឹងមានឱកាសពិភាក្សាគ្នាអំពីគោលបំណង អន្តរាគមន៍និងរបៀបធ្វើការងាររបស់កម្មវិធីអេស្កាប់។<br>៣០ នាទី | |
| **សម្ភារដែលត្រូវការ:** | ▪ ឯកសារចែក ស្តីអំពីកម្មវិធីអេស្កាប់ (ឧបសម្ព័ន្ធ៤) | |
| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
| ▪ សិក្ខាកាមអាចបកស្រាយបានពីគោលបំណង, អន្តរាគមន៍ ,សកម្មភាព និង របៀបធ្វើការងាររបសអេស្កាប់ | **៥.១.គោលបំណងកម្មវិធី**<br>▪ អ្នកសម្របសម្រួលសួររំលឹកថា: តើកម្មវិធីអេស្កាប់ជាអ្វី? ហើយកម្មវិធីមានគោលបំណងអ្វី?(បើសិក្ខាកាមឆ្លើយមិន បាន អ្នកសម្របសម្រួលបំផុសសំណួរដូចខាងក្រោម:<br>▪ អ្នកសម្របសម្រួលសួរថា:នៅក្នុងឃុំនេះតើកុមារប៉ុន្មាន% មិនបានចូលរៀន? -មានប្រជាជនជាជនជាតិប៉ុន្មាន%?<br>-សាលាមានគ្រូជាជនជាតិប៉ុន្មាននាក់?<br>-តើសាលាមានកម្មវិធីបំណិនជីវិតដែលស្របនឹងតម្រូវការរបស់សហគមន៍ឬទេ?<br>-សាលាមានគ្រូគ្រប់ទេ?បើទេ តើវាប៉ះពាល់ដល់គុណភាពបង្រៀន/រៀនឬទេ?<br>▪ អ្នកសម្របសម្រួលបិទប៉ុស្ទ័រអំពីគោលបំណងកម្មវិធីហើយពន្យល់គោលបំណងនេះ ដែលទាក់ទងទៅនឹងបញ្ហាខាងលើ។ | ▪ សិក្ខាកាមដែលធ្លាប់បានចូលសិក្ខាសាលាពីលើកមុនផ្តល់ម្លើយ ។<br>▪ សិក្ខាកាមផ្តល់ចម្លើយ ដែល ទាក់ទងទៅនឹង សេវាអប់រំ នៅក្នុងមូលដ្ឋាន ករណីអ្នកសម្រ បសម្រួលលើកសំណួរ។ |
| | **៥.២.អន្តរាគមន៍របស់កម្មវិធី**<br>▪ អ្នកសម្របសម្រួលសួរថា:តើអ្នកដឹងថា កម្មវិធីអេស្កាប់មានបទអន្តរាគមន៍ ,សកម្មភាពអ្វីខ្លះ?<br>▪ អ្នកសម្របសម្រួលពន្យល់បន្ថែម ក្នុងករណីសិក្ខាកាមផ្តល់ចម្លើយមិនគ្រាប់គ្រាន់។ | ▪ សិក្ខាកាមផ្តល់ចម្លើយនិងស្តាប់ការបកស្រាយ បន្ថែម។ |
| | **៥.៣.របៀបធ្វើការងាររបស់កម្មវិធី**<br>▪ អ្នកសម្របសម្រួលសួររំលឹក រួចទុកពេលឱ្យសិក្ខាកាមគិត ។ ក្នុងករណីដែលសិក្ខាកាមផ្តល់ចម្លើយមិនពេញលេញ អ្នកសម្របសម្រួលពន្យល់បន្ថែម។<br>▪ អ្នកសម្របសម្រួលចែកឯកសារ(ឧបសម្ព័ន្ធ៤) | ▪ សិក្ខាកាមផ្តល់ម្លើយនិងស្តាប់ការបកស្រាយបន្ថែម។ |

w

| ៦, ការចូលរួមចំនែករបស់ CEFACក្នុងការលើក កំពស់គុណភាពអប់រំ | | |
|---|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេបៈ**<br><br>**រយៈពេលៈ** | ៦ៈ ការចូលរួមចំនែករបស់ ស៊ីហ្វាក់ ថ្នាក់ឃុំ ក្នុងការលើក កំពស់គុណភាពអប់រំៈ ក្នុងមេរៀននេះ សិក្ខាកាមបានដឹងកាន់តែច្បាស់អំពីសមាសភាព **CEFAC** នៅឃុំរបស់ខ្លួន នឹង មានឱកាសពិភាក្សាទៅលើភារកិច្ចដែលកំណត់ដោយរាជរដ្ឋាភិបាលនិងទំនាក់ទំនងតួនាទី និងភារកិច្ចទាំងនេះទៅនឹងកម្មវិធីអេស្កាប់ ។<br><br>២ ម៉ោង | |
| **សម្ភារដែលត្រូវការៈ** | ▪ ផ្ទាំងក្រដាសធំ ហ្វឺត ស្កុត<br>▪ ឯកសារចែក (ឧបសម្ព័ន្ធទី៥) ស្តីអំពីភារកិច្ចរបស់គណៈស៊ីហ្វាក់ ថ្នាក់ឃុំ /សង្កាត់ | |
| **វត្ថុបំណង** | ***សកម្មភាពអ្នកសម្របសម្រួល*** | ***សកម្មភាពអ្នកចូលរួម*** |
| សិក្ខាកាមអាចៈ<br>- បង្កើនការយល់ដឹងអំពីសមាសភាពនិង ភារកិច្ច **CEFAC**<br>- កំណត់ភារកិច្ច ទាក់ទង នឹងកម្មវិធីតាមរយៈការពិភាក្សាក្នុងក្រុមតូច ។ | **៦.១. រចនាសម្ព័ន្ធស៊ីហ្វាក់ថ្នាក់ឃុំ ( ស៊ីហ្វាក់ /CEFAC)**<br>▪ អ្នកសម្របសម្រួលនិយាយថាៈយើងចង់ដឹងអំពីសមាសភាព(ឈ្មោះ) និងរចនាសម្ព័ន្ធ CEFAC ក្នុងឃុំនីមួយៗ។ សូមធ្វើការតាម ក្រុមដែលមកពីឃុំជាមួយគ្នាហើយក្រុមនីមួយៗគូររចនាសម្ព័ន្ធ នៅលើ ផ្ទាំងក្រដាសធំ ។<br>▪ អ្នកសម្របសម្រួលទុកពេលឱ្យសិក្ខាកាមពិភាក្សាតាមក្រុម ដើម្បីគូររចនាសម្ព័ន្ធ ដែលមានឈ្មោះប្រធាន អនុប្រធាន និងសមាជិក តាមការជាក់ស្តែង។<br>▪ តំណាងទាំងពីរក្រុមឡើងបិទរចនាសម្ព័ន្ធនៅលើក្តារខៀន ។<br>▪ អ្នកសម្របសម្រួលពិនិត្យឈ្មោះជាមួយនឹងលិខិតឧទេសនាមស៊ីហ្វាក់ ដែលបានទទួលពីការិយាល័យអប់រំស្រុក។ បើមានឈ្មោះខុសគ្នា សួរសិក្ខាកាមនិងតំណាងការិយាល័យអប់រំដែលមានវត្តមាននៅក្នុងសិក្ខាសាលានេះដើម្បីសុំការបំភ្លឺ។<br><br>**៦.២. ភារកិច្ចរបស់ស៊ីហ្វាក់ថ្នាក់ឃុំ /សង្កាត់ ( ស៊ីហ្វាក់ /CEFAC)**<br>▪ អ្នកសម្របសម្រួលពន្យល់សិក្ខាកាមថា រាជរដ្ឋាភិបាលបានកំណត់ ភារកិច្ចធំៗ៧ចំណុចសម្រាប់ CEFAC ក្នុងការ រួមចំនែកសម្រេច គោលដៅអប់រំសម្រាប់ទាំងអស់គ្នា។<br>▪ បន្ទាប់មក អ្នកសម្របសម្រួលបំផុសសំណួរក្នុងក្រុមធំៈ តើភារកិច្ចធំៗទាំងនោះមានអ្វីខ្លះ?<br>▪ អ្នកសម្របសម្រួលទុកពេលឱ្យសិក្ខាកាមគិតនិងពិភាក្សាគ្នាជាមួយដៃ | ▪ សិក្ខាកាមពិភាក្សាគ្នាជាក្រុម ។បន្ទាប់ពីអ្នកសម្របសម្រួលផ្តល់ឧទាហរណ៍ដ្យាក្រាម ដូចខាងក្រោមៈ<br><br>▪ សិក្ខាកាមផ្តល់ចម្លើយ ។ |

| | | |
|---|---|---|
| | គូដែលអង្គុយក្បែរគ្នា ហើយឆ្លើយ ។<br>▪ អ្នកសម្របសម្រួលចែកឯកសារ ស្តីអំពីយុទ្ធវិធីក្នុងការ សម្រេចការអប់រំសម្រាប់ទាំងអស់គ្នា និងភារកិច្ចរបស់ គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ,សង្កាត់ ។<br>▪ ក្នុងក្រុមធំៈ ពិភាក្សាលំអិតទៅលើចំណុចនីមួយៗ ដោយឱ្យសិក្ខាកាមលើកឧទាហរណ៍ឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ។ | ▪ សិក្ខាកាមផ្តល់ចម្លើយ និង សួរសំណួរ ។ |
| | **៦.៣. ទំនាក់ទំនងរវាងភារកិច្ចទាំងនេះទៅនឹងផែនការកម្រង**<br>▪ អ្នកសម្របសម្រួលសួររំលឹកឡើងវិញ ពីអន្តរាគមន៍កម្មវិធី អេស្កាប់ ។<br>▪ ចែកតារាងម៉ាទ្រីចឱ្យសិក្ខាកាមម្នាក់ៗ ។ រួចហើយផ្តល់ការណែនាំ អំពីកិច្ចការដែលត្រូវធ្វើនៅក្នុងក្រុមដោយលើក ឧទាហរណ៍មួយមកបញ្ជាក់ ។<br>▪ ទុកពេលឱ្យបានគ្រប់គ្រាន់ សម្រាប់សិក្ខាកាមពិភាក្សានិង ធ្វើកិច្ចការនេះ ដោយហ្មត់ចត់នៅក្នុងក្រុមនិមួយៗ ។ ក្រុម និមួយៗត្រូវកត់ត្រា លទ្ធផលនៃការពិភាក្សា នៅលើតារាង មួយដើម្បីផ្តល់ឱ្យអ្នកសម្របសម្រួលក្រោយពីរាយការណ៍ ហើយ ។ | ▪ សិក្ខាកាមពិភាក្សាតាមក្រុម ។ |
| | ▪ អ្នកសម្របសម្រួលគួរយកចិត្តទុកដាក់ ឱ្យបានច្រើនបំផុត ក្នុងការដើរពិនិត្យ និងជួយពន្យល់តាមក្រុមព្រោះវាជាសកម្មភាពមួយដែល យើងនឹងយកលទ្ធផលរបស់វាជាការ ប៉ាន់ប្រមាណសេចក្តីត្រូវការសម្រាប់វគ្គក្រោយ ( training needs assessment). | ▪ តំណាងក្រុមរាយការណ៍ ។ |
| | ▪ អ្នកសម្របសម្រួលធ្វើការបូកសរុប ដោយបិទផ្ទាំង ក្រដាស ធំនៅលើក្តារខៀន ប្រៀបធៀបលទ្ធផលនៃក្រុម ទាំងពីរ ។ បើយល់ថា សកម្មភាពណាមួយដែលសំខាន់ហើយក្រុមមិនទាន់បានជ្រើសរើសអាចបំផុសសំណួរ ដើម្បីជម្រុញឱ្យសិក្ខាកាមគិតថែមទៀត ។<br>▪ អ្នកសម្របសម្រួលប្រមូលកិច្ចការតាមក្រុមនិមួយៗ ដើម្បី រក្សាទុកជាឯកសារ ហើយប្រាប់សិក្ខាកាមថា សកម្មភាព ចាំបាច់មួយ ចំនួនដូចជាការបើកប្រាំឧបត្ថម្ភឱ្យគ្រូ សហគមន៍ នឹងត្រូវពិភាក្សាលំអិតនៅថ្ងៃបន្ទាប់ ។ | ▪ សិក្ខាកាមសួរសំណួរ អ្នកសម្របសម្រួលបកស្រាយ ។ |

m

## ៦. ការធ្វើផែនការ

| | |
|---|---|
| **ខ្លឹមសារនិងសេចក្តីសង្ខេប:** | វគ្គនេះផ្តល់ឱកាសឱ្យសិក្ខាកាមចាប់ផ្តើមលើកផែនការសកម្មភាពសម្រាប់ឆ្នាំសិក្សាថ្មីដែលតម្រូវអោយមានការចូលរួមពីសមាជិកគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ។ |
| **រយៈពេល:** | ៩០ នាទី |
| **សម្ភារដែលត្រូវការ:** | ▪ ឧបសម្ព័ន្ធទី ៦ តារាងផែនការ |

| *វត្ថុបំណង* | *សកម្មភាពអ្នកសម្របសម្រួល* | *សកម្មភាពសិក្ខាកាម* |
|---|---|---|
| ▪ សិក្ខាកាមធ្វើការ ឆ្លុះបញ្ចាំងសកម្មភាពការងារដែលជាប់ពាក់ពន្ធ័ ជាមួយសាលារៀនកន្លងមក និង បង្កើតផែនការសម្រាប់អនុវត្ត ផ្តើមក្នុងត្រីមាសខាងមុខ។ | ▪ អ្នកសម្របសម្រួលពន្យល់ថានៅក្នុងពេលបរិវេសនកាលនេះគឺជាពេលវេលាដែលមមាញឹកក្នុងការរៀបចំសម្រាប់ឆ្នាំសិក្សាថ្មី។ អ្នកពាក់ពន្ធ័ទាំងអស់មានការជាប់ពាក់ពន្ធ័ជាមួយសកម្មភាពជាច្រើនដើម្បីអោយប្រាកដថាការចាបលផ្តើមល្អ។អ្នកសម្របសម្រួលលើកជាសំនួរ តើមានសកម្មភាពសំខាន់ណាខ្លះនឹងចាប់ផ្តើមក្នុងត្រីមាសខាងមុខ រឺ ពីខែកញ្ញាដល់វិច្ឆការ? សិក្ខាកាមផ្តល់យោបល់របស់ពួកគេនៅក្នុងក្រុមធំ។<br>▪ អ្នកសម្របសម្រួលចែក តារាងផែនការ ឧបសម្ពន្ធ័ ៤ ជាមួយនិងកិច្ចការដែលតម្រូវអោយក្រុមស៊ីហ្វាក់រៀបចំផែនការរបស់ពួកគេស្រំរាប់ត្រីមាសខាងមុខ។ សកម្មភាពសំខាន់ៗមួយចំនួន ត្រូវបានគេសរសេររួចហើយកប៉ុន្តែសិក្ខាកាមអាចបន្ថែសកម្មភាពផ្សេងទៀតបើចាំបាច់ ។យើងគួរកត់សំកាល់ថាតារាងដែលបានចែកជូនមានបង្ហាញពេលវេលាសម្រាប់សកម្មភាពនិមួយៗ បន្តែពេលវេលាជាក់ស្តែងគួរត្រូវផ្ទៀងផ្ទាត់ជាមួយសាលារីកម្រងនិមួយៗ។ សមាជិកដោយឡែកនឹងត្រូវតែងតាំងអោយទទួលបន្ទុកការងារដោយឡែក ដើម្បីអោយប្រាកដថាសមាជិកស៊ីហ្វាក់ចូលរួមយ៉ាងសកម្មក្នុងការជួយសាលារៀនក្នុងការខិតខំប្រឹងប្រែងដើម្បីបង្កើនការចូលរៀន និង កែរលំអគុណភាពអប់រំក្នុងឆ្នាំសិក្សាថ្មី។<br><br>▪ អ្នកសម្របសម្រួលបិទសិក្ខាសាលា ដោយធ្វើការសង្ខេបកិច្ចការមួយថ្ងៃនេះ ដោយទុកឱកាសអោយសិក្ខាកាមលើកជាសំនួរ និង ផ្តល់នូវ យោបល់ត្រឡប់។ | ▪ សិក្ខាកាមធ្វើការកំនត់សកម្មភាពគន្លិះសម្រាប់អនុវត្ត ក្នុងត្រីមាសខាងមុខ។<br><br>▪ សិក្ខាកាមបែងចែកភារកិច្ច និង ការទទួលខុសត្រូវដែលចេញពីផែនការ ក្នុងត្រីមាសខាង មុខ។ |

## ឧសម្ព័ន្ធទី១ សេចក្តីសង្ខេបកម្មវិធីសាលាកុមារមេត្រី

សាលាកុមារមេត្រីជាសាលាដែលអនុវត្តកម្មវិធីអប់រំ ផ្អែកលើសិទ្ធិកុមារជាមូលដ្ឋាន ដោយមានការចូលរួម ពីគ្រប់អ្នកពាក់ព័ន្ធ ជាពិសេសមាតាបិតាសិស្ស ក្នុងការបង្កើតបរិស្ថានរៀនសូត្ររបស់សិស្ស ប្រកបដោយសាមគ្គីភាព សេរីភាព សមភាព សមធម៌ មានផាសុកភាពផ្លូវកាយ ចិត្ត ប្រាជ្ញា និង គ្មានអំពើហឹង្សា ជាពិសេសផ្តោតទៅលើការស្វែងរកកុមារឱ្យបានចូលរៀនគ្រប់គ្នា និងការសិក្សា តាមតម្រូវការសិស្ស ប្រកបដោយគុណភាព និង ប្រសិទ្ធភាព ។

**សមាសភាគទាំង៦ របស់កម្មវិធីសាលាកុមារមេត្រី**

**ផ្នែកទី១:**
**កុមារទាំងអស់បានចូលរៀន**

- បុគ្គលិកសិក្សា សហគមន៍ និងសិស្សត្រូវប្រាកដថាកុមារដែលគ្រប់អាយុ (កុមារក្រីក្រ កុមារី កុមារពិការ កុមារជនជាតិ...) មានឱកាសបានចូលរៀនទាំងអស់គ្នា
- ការរៀបចំផែនទីសិក្សា
- យុទ្ធនាការចុះឈ្មោះចូលរៀនចំពោះកុមារដែលមានអាយុ៧២ ខែ

**ការសិក្សារបស់សិស្សទាំងអស់កាន់តែប្រសើរឡើង**

**ផ្នែកទី២:**
**ការសិក្សាប្រកបដោយប្រសិទ្ធភាព**

- គ្រូកែលំអការបង្រៀនតាមរយៈការប្រើប្រាស់ឯកសារ TGL (ការសួរសំណួរ ការគ្រប់គ្រង បន្ទប់រៀន ការប្រើ ប្រាស់បរិស្ថានជាធនធាន សំរាប់បង្រៀន និងការប្រើប្រាស់ភាសារបស់ កុមារ)
- ការរៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល
- កម្មវិធីសិស្សថ្នាក់ទី១ដែលមិនបានឆ្លងមត្តេយ្យសិក្សា
- ការជួយសិស្សរៀនយឺត
- កម្មវិធីបំណិនជីវិត

**ផ្នែកទី៣:**
**សុខភាព ប្រសិទ្ធភាព និង ការការពារកុមារ**

- បុគ្គលិកសិក្សា និងសិស្សរៀបចំបរិស្ថានបន្ទប់រៀនស្អាត ប្រកបដោយសុខភាព
- កុមាររៀនពីវិធីរក្សាសុខភាព
- សាលារៀនមានបង្គន់អនាម័យ និងទឹកស្អាត
- កុមារចេះរក្សាអនាម័យផ្ទាល់ខ្លួន
- សាលារៀនផ្តល់សុវត្ថិភាព ដល់កុមារ
- សាលារៀនការពារកុមារ ឱ្យរួចផុតពីបញ្ហាផ្សេងៗ ដែលអាចប៉ះពាល់ដល់កុមារ

**ផ្នែកទី៤: ការឆ្លើយតបទៅនឹងយេនឌ័រ**

- បុគ្គលិកសិក្សា សហគមន៍ សិស្សយល់បានអំពីបញ្ហាយេនឌ័រ និងលើកកំពស់សមភាព និងសមធម៌ យេនឌ័រនៅសាលារៀន និងក្នុងសហគមន៍
- រៀបចំបង្គន់អនាម័យដោយឡែកសំរាប់កុមារា និងកុមារី
- រៀបចំព័ត៌មាន ដោយបំបែកតួលេខសិស្សប្រុសនិងសិស្សស្រី ដាច់ដោយឡែកពីគ្នា
- ការស្រាវជ្រាវពីយេនឌ័រនៅសាលារៀន និងនៅក្នុងសហគមន៍ ។

**ផ្នែកទី៥:**
**ការចូលរួមរបស់កុមារ ឪពុកម្តាយ សហគមន៍**

- គ្រួសារ និងសហគមន៍គាំទ្រយ៉ាងសកម្មដល់ការអប់រំកុមារ
- សហគមន៍ចូលរួមក្នុងការធ្វើផែនការអភិវឌ្ឍសាលារៀន ធ្វើការសម្រេចចិត្ត និងធ្វើការពិនិត្យតាមដាន
- ទស្សនកិច្ចរបស់មាតាបិតាសិស្ស / សហគមន៍
- ការជួយបង្រៀនរបស់ឪពុកម្តាយ ដល់កូនរបស់ខ្លួន នៅផ្ទះ ។

**ផ្នែកទី៦:**
**ការគាំទ្រកម្មវិធីពីប្រព័ន្ធអប់រំ**

- សកម្មភាពដែលជំរុញឱ្យមានការអនុវត្តកម្មវិធីសាលាកុមាមេត្រី (CFS) មានប្រសិទ្ធិភាព (សមាសភាគទី១ ដល់ទី៦)
- ក្រសួងអប់រំ មន្ទីរ និងការិយាល័យអប់រំ ត្រួតពិនិត្យការវិវត្ត និងវាយតំលៃកម្មវិធី CFS ។
- គណៈគ្រប់គ្រងសាលា គ្រូបង្រៀន សិស្ស និងសហគមន៍វាយតំលៃសាលារៀន ។
- ការធ្វើផែនការអភិវឌ្ឍសាលារៀន និងកំរងប្រចាំឆ្នាំ ។
- ការប្រជុំបច្ចេកទេស ។
- ការប្រជុំគណៈកម្មការកំរងប្រចាំខែ ។

**សម្ព័ន្ធទី៣ក: ការវិភាគទៅលើបញ្ញត្តិអ្នកពាក់ព័ន្ធ**

| អ្នកពាក់ព័ន្ធ | ហេតុអ្វីអ្នកចូលរួមចាប់អារម្មណ៍នឹងការធ្វើផែនការសាលារៀននិងការអភិវឌ្ឍន៍ |
|---|---|
| មាតាបិតា | o<br>o<br>o |
| គ្រូ | o<br>o<br>o |
| នាយកសាលា | o<br>o<br>o |
| សហគមន៍ | o<br>o<br>o |
| សមាគមមាតាបិតាសិស្ស | o<br>o<br>o |
| កុមារ | o<br>o<br>o |
| ក្រសួង | o<br>o<br>o |
| អាជ្ញាធរមូលដ្ឋាន | o<br>o<br>o |
| វត្តអារាម ព្រះសង្ឃ | o<br>o<br>o |

### សម្ព័ន្ធទី៣ខ: ការវិភាគទៅលើបញ្ញត្តិអ្នកពាក់ព័ន្ធ

| អ្នកពាក់ព័ន្ធ | ហេតុអ្វីអ្នកចូលរួមចាប់អារម្មណ៍នឹងការធ្វើផែនការសាលារៀននិងការអភិវឌ្ឍន៍ |
|---|---|
| មាតាបិតា | O អនាគតរបស់កូនគាត់ ផ្អែកលើគុណភាពអប់រំ ។<br>O មាតាបិតាដាក់ទុនឬផ្តល់ថវិកាដល់សាលារៀនតាមបែបផ្សេងៗគ្នា ហើយចង់ឃើញសាលារៀនមានការគ្រប់គ្រងល្អ ។ |
| គ្រូ | O ការបង្រៀន គឺជាមធ្យោបាយសម្រាប់ដោះស្រាយជីវភាពរស់នៅ ហើយគាត់ចង់បង្រៀនឱ្យបានល្អ ។<br>O គ្រូចង់បានការផ្គត់ផ្គង់ផ្នែកសម្ភារ និងធនធានផ្សេងៗទៀត ។<br>O គ្រូចង់ឃើញសម្ភាររូបវន្តនៅក្នុងសាលារៀន ត្រូវបានកែលំអ ។ |
| នាយកសាលា | O គឺជាមធ្យោបាយសម្រាប់ជីវភាពរស់នៅ ហើយគាត់ចង់គ្រប់គ្រងសាលារៀនឱ្យបានល្អ ។<br>O គាត់ទទួលខុសត្រូវចំពោះបុគ្គលិកនិងសហគមន៍ ទៅលើគុណភាពសាលារៀន ជាពិសេសការចាត់ចែង និងគ្រប់គ្រង ។ |
| សហគមន៍ | O អនាគតរបស់សហគមន៍ផ្អែកទៅលើគុណភាពអប់រំ-ពួកគាត់ចង់ឃើញសាលារៀនមានការរីកចម្រើន ព្រមទាំងមានសម្ភារ រូបវន្ត និងធនធានផ្សេងៗទៀត ។ |
| សមាគមមាតាបិតាសិស្ស | O គាត់រកប្រាក់និងធ្វើអ្វីផ្សេងៗទៀត ដើម្បីជួយសាលារៀន ។ ពួកគាត់ចង់ឱ្យមានការគ្រប់គ្រងល្អនៅក្នុង សាលារៀន និងប្រើប្រាស់ធនធានដោយឈ្លាសវៃ ។ |
| កុមារ | O ទៅសាលារៀនរៀងរាល់ថ្ងៃ ក្នុងរយៈពេល៩ខែ ក្នុងមួយឆ្នាំ-ពួកគេចង់បានសាលារៀនជាកន្លែងដែលសប្បាយរីករាយ ធ្វើឱ្យមានសុខភាពល្អ និងមានសុវត្ថិភាព ។<br>O សាលារៀនជាកន្លែងដែលគេរៀនដើម្បីអនាគតរបស់គេ-ការសិក្សារបស់គេ គួរតែមានគុណភាព ។ |
| ក្រសួង | O បើកប្រាក់ខែឱ្យគ្រូនិងការចំណាយផ្សេងៗទៀត - ក្រសួងចង់ឃើញលទ្ធផលល្អពីការចំណាយនេះ ហើយរំពឹងចង់ឃើញការគ្រប់គ្រងនិងចាត់ចែងល្អ ។ |
| អាជ្ញាធរមូលដ្ឋាន | O ពួកគាត់ចង់ឃើញការគ្រប់គ្រង /ចាត់ចែងនិងលទ្ធផលអប់រំល្អសម្រាប់កុមារនៅក្នុងស្រុក ។ |
| វត្តអារាម ព្រះសង្ឃ | O ព្រះសង្ឃនិងគណៈកម្មការវត្តចំណាយប្រាក់ ដើម្បីថែរក្សានិងពង្រីកសាលារៀន ហើយចង់ឃើញសាលារៀនមានការគ្រប់គ្រង /ចាត់ចែងល្អ ។ |

## ឧបសម្ព័ន្ធទី៥៖ ភារកិច្ចរបស់គណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ/សង្កាត់

---

- រៀបចំផែនការនិងអភិវឌ្ឍកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា ឱ្យបានសមស្របតាមគោលដៅរបស់ជាតិ ខេត្ត /ក្រុង ស្រុក /ខ័ណ្ឌ និងស្ថានភាពជាក់ស្តែងរបស់មូលដ្ឋាន ។
- បំផុសស្មារតីរបស់ប្រជាពលរដ្ឋ និង អ្នកដឹកនាំក្នុងមូលដ្ឋានឱ្យចូលរួមក្នុងកម្មវិធីឱ្យបានច្រើន ។
- កៀរគរ និងប្រើប្រាស់ធនធានដែលមាននៅក្នុងមូលដ្ឋាន ។
- សម្របសម្រួលជាមួយគ្រឹះស្ថានសិក្សានានា និងភ្នាក់ងារមូលដ្ឋានដទៃទៀត ។
- ធ្វើការប្រជុំតាមការចាំបាច់ ដើម្បីវាយតម្លៃការងារដែលដាក់ចុះ ។
- ចុះតាមដានវាយតម្លៃសកម្មភាពអប់រំសម្រាប់ទាំងអស់គ្នាតាមភូមិជាប្រចាំ ។
- រៀបចំរបាយការណ៍ជារៀងរាល់ខែ ផ្ញើជូនគណៈកម្មាធិការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ស្រុក /ខ័ណ្ឌ ។

---

*(ដកស្រង់ចេញពីឯកសារ " ការអប់រំសម្រាប់ទាំងអស់គ្នា " របស់រាជរដ្ឋាភិបាល ។)*

## ឧបសម្ពន្ធ័ទី ៦ : តារាងផែនការ ឆ្នាំទី២

សម្រាប់ក្នុងត្រីមាស (ពីខែកញ្ញា ដល់ វិច្ឆការ)

| សកម្មភាព | ពេលវេលា | អ្នកណា? | ធ្វើយ៉ាងដូចម្តេច? |
|---|---|---|---|
| ផែនការសាលារៀន<br>(PAP) | សីហា - កញ្ញា<br>August-September | | |
| ផែនការកម្រង<br>សាលារៀន<br>(ESCUP) | កញ្ញា<br>September | | |
| គូរផែនទីរកកុមារ<br>Child-seeking school/ school mapping | កញ្ញា- តុលា<br>September -October | | |
| បែងចែកអាហារូបករណ៏សិស្ស<br>Scholarship program | September -October-November | | |
| ផ្សេងទៀត<br>Other?<br>(District Integration Workshop) | | | |